**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ...៣៣៩៨...អពដ

# សារលិខិតចូលរួមមរណទុក្ខ

**សូមគោរពជូន**
**លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអគ្គនាយកដ្ឋានពន្ធដារ និងក្នុងនាមខ្ញុំផ្ទាល់ យើងខ្ញុំទាំងអស់គ្នាមានសេចក្តីក្តុកក្តួល រន្ធត់ឥតឧបមា ដោយបានទទួលដំណឹងថា **ឯកឧត្តម នាយឧត្តមសេនីយ៍ ម៉េង ង៉ាត់** សមាជិកព្រឹទ្ធសភា និងជាសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈនៃព្រឹទ្ធសភា បានទទួលមរណភាពកាលពីវេលាម៉ោង ០១:៣៥ នាទី រំលងអធ្រាត ថ្ងៃពុធ ទី០២ ខែមីនា ឆ្នាំ២០១៥ ក្នុងជន្មាយុ ៦៦ ឆ្នាំ ដោយរោគាពាធ។

ការបាត់បង់**ឯកឧត្តមនាយឧត្តមសេនីយ៍ ម៉េង ង៉ាត់** គឺជាការបាត់បង់វីរជនខ្មែរមួយរូប ដែលបានបូជាកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី ចូលរួមការពារ កសាង អភិវឌ្ឍន៍មាតុភូមិកម្ពុជាជាទីស្រឡាញ់នៃយើង រហូតទទួលបានការរីកចម្រើនដូចសព្វថ្ងៃ និងជាការបាត់បង់ស្វាមី បិតា ជីតា ជាទីគោរពស្រឡាញ់ និងប្រកបដោយព្រហ្មវិហារធម៌ និងទឹកចិត្តសណ្តោសប្រណីដ៏ថ្លៃថ្លា។

ស្ថិតក្នុងសមានទុក្ខ វិយោគសោកស្តាយរកទីបំផុតគ្មាននាឱកាសនេះ យើងខ្ញុំសូមចូលរួមសម្តែងមរណទុក្ខ និងក្តីអាឡោះអាល័យ ជាមួយ**លោកជំទាវឧបនាយករដ្ឋមន្ត្រី** និងក្រុមគ្រួសារ និងសូមបួងសួងសូមដួងវិញ្ញាណក្ខន្ធ**ឯកឧត្តមនាយឧត្តមសេនីយ៍ ម៉េង ង៉ាត់** ឆាប់បានយោនយកកំណើតកើតក្នុងសុគតិភពគ្រប់ៗ ជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូមលោកជំទាវឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុត ពីខ្ញុំ

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៦

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**